# វិធីសាស្ត្រសម្រេចចិត្ត សម្រាប់ការពិនិត្យតាមដានរោគសញ្ញា នៅមណ្ឌលថែទាំនិងអប់រំកុមារតូច និងសាលារៀនកម្រិត TK-12

*នាយកដ្ឋានសុខភាពសាធារណៈនៃខោនធី Los Angeles*
*បានធ្វើបច្ចុប្បន្នកម្ម៖ 8/15/2022*

# វិធីសាស្ត្រសម្រេចចិត្តសម្រាប់*កុមារ*ដែលមានរោគសញ្ញា

# វិធីសាស្ត្រសម្រេចចិត្តសម្រាប់កុមារដែលមានរោគសញ្ញា មុនពេលចូល[1] ទៅក្នុងស្ថាប័នអប់រំ ដោយមិនគិតអំពីស្ថានភាពនៃការចាក់ថ្នាំបង្ការ

[1]ប្រសិនបើកុមារមិនស្រួលខ្លួននៅទីតាំងនោះ សូមដាក់កុមារឱ្យនៅដាច់ដោយឡែក (ឆ្ងាយពីអ្នកមើលថែ យកល្អដាក់កុមារនៅទីធ្លាខាងក្រៅអគារ) ហើយអនុវត្តតាមវិធីសាស្ត្រសម្រេចចិត្តដូចដែលបានពិពណ៌នាខាងក្រោម។

ការត្រួតពិនិត្យកំណត់អត្តសញ្ញាណកុមារដែលមានរោគសញ្ញា 1 ឬច្រើនជាងនេះ ហើយដែល<u>ទំនងជាស្របទៅនឹងជំងឺ COVID-19</u>។[1] →

កុមារត្រូវបញ្ជូនទៅផ្ទះវិញ។ ឪពុកម្តាយ/អាណាព្យាបាលត្រូវបានណែនាំឱ្យពិគ្រោះជាមួយអ្នកផ្តល់សេវាកម្មផ្នែកវេជ្ជសាស្ត្រសម្រាប់ការវាយតម្លៃបន្ថែមទៀត និងអាចមានការធ្វើតេស្តរកជំងឺ COVID-19។

- អ្នកផ្តល់សេវាកម្មផ្នែកវេជ្ជសាស្ត្របញ្ជាក់ថា កុមារមិនមានរោគសញ្ញាដែលស្របទៅនឹងជំងឺ COVID-19 ទេ។ → កុមារត្រូវនៅផ្ទះដោយអនុវត្តតាមសេចក្តីណែនាំរបស់អ្នកផ្តល់សេវាកម្មផ្នែកវេជ្ជសាស្ត្រ។
- មិនបានពិគ្រោះជំងឺជាមួយអ្នកផ្តល់សេវាកម្មផ្នែកវេជ្ជសាស្ត្រ ឬអ្នកផ្តល់សេវាកម្មផ្នែកវេជ្ជសាស្ត្របញ្ជាក់ថា កុមារមានរោគសញ្ញាដែលស្របទៅនឹងជំងឺ COVID-19។
  - កុមារបានធ្វើតេស្តរកមេរោគ:
    - កុមារទទួលលទ្ធផល**អវិជ្ជមាន**ពីការធ្វើតេស្តត្រួតពិនិត្យជំងឺ COVID-19[2] → កុមារនៅផ្ទះរហូតដល់លែងមានគ្រុនក្តៅ ដោយមិនប្រើប្រាស់ថ្នាំបញ្ចុះកម្តៅសម្រាប់រយៈពេល 24 ម៉ោង និងរោគសញ្ញាកាន់តែធូរស្បើយឡើង។
    - កុមារទទួលលទ្ធផល**វិជ្ជមាន**ពីការធ្វើតេស្តត្រួតពិនិត្យជំងឺ COVID-19[2] → កុមារត្រូវអនុវត្តតាម<u>សេចក្តីណែនាំនៃការដាក់ខ្លួនឱ្យនៅដាច់ដោយឡែកនៅផ្ទះ</u>។
  - កុមារមិនបានធ្វើតេស្តរកមេរោគ → កុមារត្រូវអនុវត្តតាម<u>សេចក្តីណែនាំនៃការដាក់ខ្លួនឱ្យនៅដាច់ដោយឡែកនៅផ្ទះ</u>។

ការត្រួតពិនិត្យកំណត់អត្តសញ្ញាណកុមារដែលមានរោគសញ្ញាដែល<u>មិន</u>ទំនងជាស្របទៅនឹងជំងឺ COVID-19។ →

ស្ថាប័នសម្រេចចិត្តក្នុងការកំណត់ថា តើកុមារគួរតែត្រូវបានលើកលែងតាមគោលការណ៍គ្រប់គ្រងជំងឺឬទេ។ ប្រសិនបើរោគសញ្ញារបស់កុមារធ្វើឱ្យមានការលំបាកក្នុងការអនុវត្តតាមពិធីការសុវត្ថិភាពសម្រាប់ជំងឺ COVID-19 នៅក្នុងទីតាំងនោះ កុមារគួរតែត្រូវបញ្ជូនទៅផ្ទះវិញ។

[1]រោគសញ្ញានានាដែលទំនងជាស្របទៅនឹងការឆ្លងជំងឺ COVID-19 ចំពោះកុមាររួមមាន៖ គ្រុនក្តៅលើសឬស្មើ (≥) 100.4°F ក្អកកើតឡើងថ្មី (ខុសគ្នាពីធម្មតាឬទូទៅ) ក្អួតចង្អោរ ឬចាប់ផ្តើមមានការរាគរូសថ្មី។ ប្រសិនបើរោគសញ្ញារបស់កុមារមិនទំនងជាស្របទៅនឹងជំងឺ COVID-19 ទេ ប៉ុន្តែនៅតែមានការព្រួយបារម្ភនោះ មានការណែនាំឱ្យទទួលការវាយតម្លៃរបស់កុមារពីអ្នកផ្តល់សេវាកម្មផ្នែកវេជ្ជសាស្ត្រ។

[2] ការធ្វើតេស្តពិនិត្យរកមេរោគ COVID-19 រួមមានទាំងការធ្វើតេស្តពង្រីកអាស៊ីដនុយក្លេអ៊ិច (NAATs) ដូចជាការធ្វើតេស្តរកទម្រង់មេរោគ (PCR) ឬការធ្វើតេស្តរកសារធាតុដែលបញ្ចូលក្នុងខ្លួនដើម្បីបង្កើតភាពស៊ាំ (antigen) បែបរហ័ស (រួមទាំងតេស្តដែលអាចទិញបានដោយមិនចាំបាច់មានវេជ្ជបញ្ជា ឬតេស្តនៅផ្ទះផងដែរ)។ ការធ្វើតេស្តប្រភេទ PCR ត្រូវបានចាត់ទុកថាជាប្រភេទតេស្តសម្រាប់ពិនិត្យរកជំងឺ COVID-19 ដែលផ្តល់លទ្ធផលច្បាស់លាស់បំផុត ប៉ុន្តែអាចនឹងប្រើប្រាស់តេស្តប្រភេទ PCR ក៏បាន ឬក៏តេស្តប្រភេទ antigen បែបរហ័ស ក៏បាន។

# វិធីសាស្រ្តសម្រេចចិត្តសម្រាប់*បុគ្គលិក*ដែលមានរោគសញ្ញា

# វិធីសាស្ត្រសម្រេចចិត្ត សម្រាប់បុគ្គលិកដែលមានរោគសញ្ញា មុនពេលចូល[1] ទៅក្នុង ស្ថាប័នអប់រំ ដោយមិនគិតអំពីស្ថានភាពនៃការចាក់ថ្នាំបង្ការ

[1]ប្រសិនបើបុគ្គលិកមិនស្រួលខ្លួននៅកន្លែងការងារ សូមដាក់បុគ្គលិកនៅទីតាំងដាច់ដោយឡែក (យកល្អដាក់បុគ្គលិកនៅទីធ្លាខាងក្រៅអគារ រក្សាគម្លាតរាងកាយពីអ្នកមើលថែផ្សេងទៀត) ហើយអនុវត្តតាមវិធីសាស្ត្រសម្រេចចិត្តដូចខាងក្រោម។

ការត្រួតពិនិត្យកំណត់អត្តសញ្ញាណបុគ្គលិកដែលមានរោគសញ្ញា 1 ឬច្រើនជាងនេះ <u>ដែលទំនងជាស្របទៅនឹងជំងឺ COVID-19</u>។[1] →

បុគ្គលិកត្រូវបញ្ជូនឱ្យត្រឡប់ទៅផ្ទះវិញ ហើយត្រូវបានណែនាំឱ្យពិគ្រោះជាមួយអ្នកផ្តល់សេវាកម្មផ្នែកវេជ្ជសាស្ត្រសម្រាប់ការវាយតម្លៃបន្ថែមទៀត និងការធ្វើតេស្តរកជំងឺ COVID-19 ដែលអាចកើតមាន។

- អ្នកផ្តល់សេវាកម្មផ្នែកវេជ្ជសាស្ត្របញ្ជាក់ថា បុគ្គលិកមិនមានរោគសញ្ញាដែលស្របទៅនឹងជំងឺ COVID-19 ទេ។ → បុគ្គលិកត្រូវនៅផ្ទះដោយអនុវត្តតាម សេចក្តីណែនាំរបស់អ្នកផ្តល់សេវាកម្មផ្នែកវេជ្ជសាស្ត្រ។
- មិនបានពិគ្រោះយោបល់ជាមួយអ្នកផ្តល់សេវាកម្មផ្នែកវេជ្ជសាស្ត្រទេ ឬអ្នកផ្តល់សេវាកម្មផ្នែកវេជ្ជសាស្ត្របញ្ជាក់ថាបុគ្គលិកមានរោគសញ្ញាដែលស្របទៅនឹងជំងឺ COVID-19។
  - បុគ្គលិកបានធ្វើតេស្តរកមេរោគ:
    - បុគ្គលិកទទួលលទ្ធផល **អវិជ្ជមាន**ពីការធ្វើតេស្តត្រួតពិនិត្យជំងឺ COVID-19 [2] → បុគ្គលិកត្រូវនៅផ្ទះរហូតដល់លែងមានគ្រុនក្តៅ ដោយមិនប្រើប្រាស់ថ្នាំបញ្ចុះកម្តៅ សម្រាប់រយៈពេល 24 ម៉ោង និងរោគសញ្ញាកាន់តែធូរស្បើយឡើង។
    - បុគ្គលិកទទួលលទ្ធផល **វិជ្ជមាន**ពីការធ្វើតេស្តត្រួតពិនិត្យជំងឺ COVID-19 [2] → បុគ្គលិកត្រូវអនុវត្តតាម <u>សេចក្តីណែនាំនៃការខ្លួនដាក់ឱ្យនៅដាច់ដោយឡែកនៅផ្ទះ</u>។
  - បុគ្គលិកមិនបានធ្វើតេស្តរកមេរោគ → បុគ្គលិកត្រូវអនុវត្តតាម <u>សេចក្តីណែនាំនៃការខ្លួនដាក់ឱ្យនៅដាច់ដោយឡែកនៅផ្ទះ</u>។

ការត្រួតពិនិត្យកំណត់អត្តសញ្ញាណបុគ្គលិកដែលមានរោគសញ្ញា ហើយដែល<u>មិន</u>ទំនងជាស្របទៅនឹងជំងឺ COVID-19។ →

ស្ថាប័នសម្រេចចិត្តក្នុងការកំណត់ថា តើបុគ្គលិកគួរតែត្រូវបានលើកលែងតាមគោលការណ៍គ្រប់គ្រងជំងឺឬទេ។ ប្រសិនបើរោគសញ្ញារបស់បុគ្គលិកធ្វើឱ្យមានការលំបាកក្នុងការអនុវត្តតាមពិធីការសុវត្ថិភាពសម្រាប់ជំងឺ COVID-19 នៅក្នុងទីតាំងនោះ បុគ្គលិកគួរតែត្រូវបញ្ជូនឱ្យត្រឡប់ទៅផ្ទះវិញ។

[1]រោគសញ្ញានានាដែលទំនងជាពាក់ព័ន្ធទៅនឹងជំងឺ COVID-19 ចំពោះមនុស្សពេញវ័យមានដូចជា៖ គ្រុនក្តៅលើសពីឬស្មើ (≥) 100.4° ឬមានអារម្មណ៍ដូចគ្រុនក្តៅ (គ្រុនរងា បែកញើស) ក្អក ដកដង្ហើមខ្លីៗ លែងដឹងរសជាតិឬក្លិនថ្មីៗ អស់កម្លាំង ហៀរសំបោរឬតឹងច្រមុះ ឈឺសាច់ដុំឬឈឺរាងកាយ ឈឺក្បាល ឈឺបំពង់ក ចង្អោរចង់ក្អួតឬក្អួត រាគរូស។ ប្រសិនបើមានរោគសញ្ញាដែលមិនមាននៅក្នុងតារាងនេះទេ ប៉ុន្តែនៅតែមានការព្រួយបារម្ភ មានការណែនាំឱ្យទទួលការវាយតម្លៃបន្ថែមដោយអ្នកផ្តល់សេវាកម្មផ្នែកវេជ្ជសាស្ត្រ។

[2] ការធ្វើតេស្តពិនិត្យរកមេរោគ COVID-19 រួមមានទាំងការធ្វើតេស្តពង្រីកអាស៊ីដនុយក្លេអ៊ិច (NAATs) ដូចជាការធ្វើតេស្តរកទម្រង់មេរោគ (PCR) ឬការធ្វើតេស្តរកសារធាតុដែលបញ្ចូលក្នុងខ្លួនដើម្បីបង្កើតភាពស៊ាំ (antigen) បែបរហ័ស (រួមទាំងតេស្តដែលអាចទិញបានដោយមិនចាំបាច់មានវេជ្ជបញ្ជា ឬតេស្តនៅផ្ទះផងដែរ)។ ការធ្វើតេស្តប្រភេទ PCR ត្រូវបានចាត់ទុកថាជាប្រភេទតេស្តសម្រាប់ពិនិត្យរកជំងឺ COVID-19 ដែលផ្តល់លទ្ធផលច្បាស់លាស់បំផុត ប៉ុន្តែអាចនឹងប្រើប្រាស់តេស្តប្រភេទ PCR ក៏បាន ឬក៏តេស្តប្រភេទ antigen បែបរហ័ស ក៏បាន។

# **វិធីសាស្រ្តសម្រេចចិត្តសម្រាប់** *អ្នកដែលមានទំនាក់ទំនង (កុមារ/សិស្ស ឬបុគ្គលិក/អ្នកធ្វើការ)* *ជាមួយនឹងបុគ្គលដែលទំនងជាអាចឆ្លងមេរោគ*

# វិធីសាស្ត្រសម្រេចចិត្ត សម្រាប់អ្នកដែលមានទំនាក់ទំនងទៅនឹងបុគ្គលដែលទំនងជាអាចឆ្លងមេរោគ នៅក្នុងស្ថាប័នអប់រំ

**បុគ្គលដែលទំនងជាអាចឆ្លងមេរោគ** គឺជាបុគ្គលម្នាក់ដែលមានរោគសញ្ញាលើសពីឬស្មើ (≥) 1 ហើយដែលទំនងជាស្របទៅនឹងជំងឺ COVID-19[1]។ នៅតាមទីតាំងសាលារៀនកម្រិត TK-12 ព្រមទាំងទីតាំងថែទាំនិងអប់រំកុមារតូច (ECE) **អ្នកដែលមានទំនាក់ទំនងជិតស្និទ្ធទៅនឹងបុគ្គលដែលទំនងជាអាចឆ្លងមេរោគ** គឺជាបុគ្គលទាំងឡាយដែលស្ថិតនៅទីលំហបរិយាកាសខាងក្នុងអគាររួមគ្នា ឬស្ថិតនៅក្នុងបរិវេណ 6 ហ្វីតពីបុគ្គលដែលមានជំងឺ COVID-19 បានរយៈពេលសរុបចាប់ពី 15 នាទីឡើងទៅ ក្នុងអំឡុងពេល 24 ម៉ោង ខណៈពេលដែលពួកគេអាចចម្លងមេរោគបន្តបាន[2]។

អ្នកដែលមានទំនាក់ទំនងទៅនឹងបុគ្គលដែលអាចមានឆ្លងមេរោគ ត្រូវបានជូនដំណឹងថាពួកគេអាចមានការប៉ះពាល់ទៅនឹងមេរោគ។

បុគ្គលដែលមានទំនាក់ទំនងអាចបន្តស្ថិតនៅទីតាំងនោះ ខណៈពេលដែលកំពុងរង់ចាំ **ការបញ្ជាក់ពីការប៉ះពាល់ទៅនឹងមេរោគ។[3]**

→ ស្ថាប័នបញ្ជាក់ថា បុគ្គលដែលមានទំនាក់ទំនងនោះ បានប៉ះពាល់ទៅនឹងជំងឺ COVID-19។

→ ស្ថាប័នបញ្ជាក់ថា បុគ្គលដែលមានទំនាក់ទំនង មិនបានប៉ះពាល់ទៅនឹងមេរោគទេ ឬក៏មិនមានការផ្តល់ការបញ្ជាក់អំពីការប៉ះពាល់ទៅនឹងមេរោគ។ **មិនតម្រូវចាំបាច់ឱ្យធ្វើសកម្មភាពអ្វីទេ។**

បុគ្គលដែលមានទំនាក់ទំនងជិតស្និទ្ធហើយដែលមិនមានរោគសញ្ញា មិនចាំបាច់ធ្វើចត្តាឡីស័កឡើយ ប៉ុន្តែតម្រូវចាំបាច់ឱ្យ៖

(1) តាមដានចំពោះរោគសញ្ញាសម្រាប់រយៈពេល 10 ថ្ងៃ បន្ទាប់ពីការប៉ះពាល់ទៅនឹងមេរោគចុងក្រោយ។
(2) ប្រសិនបើមានអាយុចាប់ពី 2 ឆ្នាំឡើងទៅ ពាក់ម៉ាស់ដែលមានកម្រិតការពារល្អណាស់ពេលនៅជិតអ្នកដទៃខណៈនៅក្នុងអគារ លើកលែងតែពេលកំពុងបរិភោគអាហារឬភេសជ្ជៈ សម្រាប់រយៈពេល 10 ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទចុងក្រោយនៃការប៉ះពាល់ទៅនឹងមេរោគ។*
(3) ធ្វើតេស្តដោយប្រើប្រាស់ឧបករណ៍ធ្វើតេស្តរកមេរោគ COVID-19 ដែលបានទទួលការអនុញ្ញាតឱ្យប្រើប្រាស់ដោយរដ្ឋបាលចំណីអាហារនិងឱសថ (FDA) (ឧទាហរណ៍ ការធ្វើតេស្តរកទម្រង់មេរោគ [PCR] ឬ ការធ្វើតេស្តរកសារធាតុដែលបញ្ចូលក្នុងខ្លួនដើម្បីបង្កើតភាពស៊ាំ [Antigen] រួមទាំងការធ្វើតេស្តនៅផ្ទះផងដែរ) ក្នុងអំឡុងពេល 3 ទៅ 5 ថ្ងៃចាប់តាំងពីកាលបរិច្ឆេទចុងក្រោយនៃការប៉ះពាល់ទៅនឹងមេរោគ។ **

*សិស្ស/កុមារ អាយុចាប់ពី 2 ឆ្នាំឡើងទៅ ដែលមានការលើកលែងចំពោះការពាក់ម៉ាស់ អាចពាក់របាំងមុខដែលមានក្រណាត់រុំនៅគែមខាងក្រោម ឬត្រូវតែធ្វើតេស្តចំនួនម្តង នៅចន្លោះថ្ងៃទី 3 និងទី 5 ហើយម្តងទៀត នៅចន្លោះថ្ងៃទី 6 និងទី 9 ដើម្បីបន្តស្ថិតនៅទីតាំងបាន។ កុមារដែលមានអាយុក្រោម 2 ឆ្នាំ**មិន**គួរពាក់ម៉ាស់ទេ។ សូមយោងទៅលើ ផែនការគ្រប់គ្រងការប៉ះពាល់ទៅនឹងមេរោគសម្រាប់សាលារៀនកម្រិត TK-12 ឬ ផែនការគ្រប់គ្រងការប៉ះពាល់ទៅនឹងមេរោគសម្រាប់ទីតាំងថែទាំនិងអប់រំកុមារតូច (ECE) សម្រាប់ព័ត៌មានលម្អិតបន្ថែមទៀត។

**ប្រសិនបើអ្នកធ្លាប់មានជំងឺ COVID-19 ក្នុងអំឡុងពេល 90 ថ្ងៃកន្លងមកនេះ អ្នកមិនចាំបាច់ធ្វើតេស្តទេ លុះត្រាតែអ្នកកើតមានរោគសញ្ញា។

ប្រសិនបើប្រើប្រាស់និយមន័យដែលថា បានស្ថិតនៅក្នុងបរិវេណ 6 ហ្វីតពីអ្នកឆ្លងមេរោគ បានរយៈពេលចាប់ពី 15 នាទីឡើងទៅក្នុងអំឡុងពេល 24 ម៉ោង សម្រាប់បុគ្គលដែលមានទំនាក់ទំនងជិតស្និទ្ធនៅក្នុងថ្នាក់រៀន ឬទីតាំងដែលមានទំហំប្រហាក់ប្រហែលនឹងគ្នានេះ បុគ្គលផ្សេងទៀតទាំងអស់ដែលស្ថិតនៅទីលំហបរិយាកាសខាងក្នុងអគាររួមគ្នាជាមួយនឹងអ្នកឆ្លងមេរោគ បានរយៈពេលចាប់ពី 15 នាទី ឡើងទៅ ក្នុងអំឡុងពេល 24 ម៉ោង ត្រូវតែបានជូនដំណឹងថា ពួកគេទំនងជាបានប៉ះពាល់ទៅនឹងមេរោគ ហើយមានការណែនាំយ៉ាងម៉ឺងម៉ាត់ឱ្យអនុវត្តតាមសេចក្តីណែនាំខាងលើចំពោះការតាមដានរោគសញ្ញា ការពាក់ម៉ាស់ (ប្រសិនបើមានអាយុចាប់ពី 2 ឆ្នាំឡើងទៅ) និងការធ្វើតេស្តរកមេរោគ។

[1] **រោគសញ្ញា** ដែលស្របទៅនឹងលក្ខខ័ណ្ឌនៃជំងឺ COVID-19 មានភាពខុសគ្នាចំពោះកុមារនិងមនុស្សពេញវ័យ សូមមើលស្លាយលេខ 3 សម្រាប់លក្ខខ័ណ្ឌរបស់កុមារ និងស្លាយលេខ 5 សម្រាប់លក្ខខ័ណ្ឌរបស់មនុស្សពេញវ័យ។
[2] មានមធ្យោបាយផ្សេងៗគ្នាក្នុងការកំណត់អត្តសញ្ញាណនៃបុគ្គលដែលមានទំនាក់ទំនងជិតស្និទ្ធនៅក្នុងទីតាំងថែទាំនិងអប់រំកុមារតូច (ECE) សាលារៀនកម្រិត TK-12 និងស្ថាប័នអប់រំជាន់ខ្ពស់ (IHE)។ សូមយោងទៅលើផែនការគ្រប់គ្រងការប៉ះពាល់ទៅនឹងមេរោគដែលពាក់ព័ន្ធទៅនឹងទីតាំងទាំងនេះ សម្រាប់ព័ត៌មានលម្អិត៖ ទីតាំងថែទាំនិងអប់រំកុមារតូច (ECE) ឬ សាលារៀនកម្រិត TK-12 ឬក៏ ស្ថាប័នអប់រំជាន់ខ្ពស់ (IHE)។

[3]**ការប៉ះពាល់ទៅនឹងមេរោគត្រូវបានបញ្ជាក់** សម្រាប់បុគ្គលដែលមានទំនាក់ទំនងជិតស្និទ្ធជាមួយនឹងកុមារដែលទំនងជាអាចមានឆ្លងមេរោគ ប្រសិនបើទីតាំងនោះទទួលបានដំណឹងថាកុមារដែលទំនងជាអាចមានឆ្លងមេរោគនោះ បានទទួលលទ្ធផលវិជ្ជមានពីការធ្វើតេស្តត្រួតពិនិត្យជំងឺ COVID-19 ឬក៏ទទួលការធ្វើរោគវិនិច្ឆ័យជំងឺ COVID-19 ពីអ្នកផ្តល់សេវាកម្មផ្នែកវេជ្ជសាស្ត្រ។